UNITE714.UNITE714.

ការរួបរួម 714

អធិស្ថាន សប្តាហ៍ ទី៧

ឧសភា ទី០៣ ដល់ ឧសភា ទី ៩

ហេតុនោះបានជាត្រូវឲ្យយកគ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទប់ទល់ក្នុងថ្ងៃអាក្រក់បាន រួចកាលណាបានតតាំងសព្វគ្រប់ហើយ នោះឲ្យបាននៅតែឈរមាំមួនដដែល ដូច្នេះ ចូរឲ្យឈរមាំមួនចុះ។

— **អេភេសូ ៦:១៣-១៤ក**

ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើមានសេចក្តីជំនឿតតសង្ស័យសោះ នោះអ្នករាល់គ្នានឹងអាចធ្វើបាន មិនត្រឹមតែការដែលកើតឡើងដល់ដើមល្វាប៉ុណ្ណោះទេ គឺទោះបើអ្នកនឹងនិយាយទៅភ្នំនេះថា ឲ្យឯងរើចេញពីទីនេះទៅធ្លាក់ក្នុងសមុទ្រវិញ នោះគង់តែនឹងបានកើតដូច្នោះដែរ ។

— **ម៉ាថាយ ២១:២១**

អធិស្ថាន

ឱព្រះវរបិតានៃស្ថានសួគ៌អើយ អស់រយៈពេលជាច្រើនសប្តាហ៍មកហើយ ដែលយើងខ្ញុំបានរស់នៅក្រោមការគំរាមកំហែងឥតឈប់ឈរពីជំងឺកូវីត១៩។ វាបានវាយប្រហារ ដោយព័ត៌មានអាក្រក់ និងដោយការនៅដាច់ដោយឡែកតែនៅក្នុងផ្ទះ នោះយើងខ្ញុំបានប្រឈមមុខនឹងការព្រួយបារម្ភយ៉ាងខ្លាំង ដោយអាចប្រឈមនឹងការកើតជំងឺនេះ ឬក៏រួមនឹងផលលំបាកផ្នែកហិរញ្ញវត្ថុទៀតផង។ អស់ជាច្រើនថ្ងៃកន្លងមកនេះ យើងខ្ញុំបានតស៊ូជំនះ ដើម្បីឈរក្នុងជំនឿ ។ ប៉ុន្តែនោះគឺដោយសារតែព្រះចេស្តា និងព្រះគុណរបស់ទ្រង់ ទើបយើងខ្ញុំក្រោកឈរឡើងបាន។

យើងខ្ញុំបំពាក់គ្រឿងសឹកខាងវិញ្ញាណរបស់យើងខ្ញុំនៅថ្ងៃនេះ តាមរយៈសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ត។ យើងខ្ញុំអធិស្ថានប្រឆាំងនឹងជំងឺកូវីដ១៩ ដោយព្រះបន្ទូលរបស់ព្រះ និងតាមរយៈអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ យើងខ្ញុំទប់ទល់នឹងផលប៉ះពាល់ទាំងអស់នៃជំងឺកូវីដ១៩ មកលើយើងខ្ញុំ ក្រុមគ្រួសារយើងខ្ញុំ ពួកជំនុំ ទីក្រុង និងប្រជាជាតិនានា។

-

វីរុសនេះមានឥទ្ធិពលលើប្រជាជាតិនានាលើសកលលោក ហើយបានឈានដល់គ្រប់ទិដ្ឋភាពនៃសង្គមនីមួយៗ។ ទោះបីមានការប្រឈមបែបនេះក៏ដោយ យើងខ្ញុំក៏នៅតែឈរឡើងនៅចំពោះមុខជំងឺកូវីដ១៩ ហើយប្រកាសថា " ព្រះរបស់យើងខ្ញុំអាចរំដោះយើងខ្ញុំបាន!"

ឱព្រះអម្ចាស់អើយ យើងខ្ញុំទូលសុំដោយសេចក្តីមេត្តាករុណាដ៏អស្ចារ្យរបស់ទ្រង់ សូមឲ្យជំងឺកូវីដ១៩ត្រូវលុបបំបាត់ចោល ហើយក្នុងពេលឆាប់ៗនេះ យើងខ្ញុំនឹងមើលឃើញជំងឺនេះរលាយទៅបាត់គ្មានសល់។

ឱព្រះវរបិតានៃស្ថានសួគ៌អើយ សូមបង្កើនសេចក្តីជំនឿរបស់យើងខ្ញុំ។ សូមធ្វើការនៅក្នុងដួងចិត្តរបស់យើងខ្ញុំ។ ឱព្រះអម្ចាស់អើយ សូមបង្កើតចរិតលក្ខណៈរបស់ទ្រង់នៅក្នុងយើងខ្ញុំ ។ ព្រះអង្គបានបង្ហាញដល់យើងខ្ញុំនូវសេចក្តីមេត្តាករុណា និងព្រះគុណរបស់ព្រះអង្គរាប់មិនអស់ឡើយ។ យើងខ្ញុំសូមថ្លែងអំណរគុណ និងទូលសុំដោយបន្ទាបខ្លួន សូមទ្រង់ប្រទានព្រះវិញ្ញាណបរិសុទ្ធជាថ្មី មកលើប្រជាជននៅលើសកលលោក។ សូមឲ្យមនុស្សរាប់លាននាក់បានសង្គ្រោះ និងត្រូវបានបង្រៀនឲ្យក្លាយជាសិស្សរបស់ទ្រង់ ក្នុងពេលពួកជំនុំរបស់ទ្រង់ប្រកាសដំណឹងល្អដោយក្លាហាន ក្នុងគ្រាដ៏លំបាកនេះ។

នេះគឺជាការអធិស្ថាន និងការជឿទុកចិត្តរបស់យើងខ្ញុំ តាមរយៈអំណាចដ៏មានព្រះចេស្តាបំផុតរបស់ព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់របស់យើងខ្ញុំ។ អាមែន។